# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាសម្រាប់គ្រូអប់រំជំនឿ និងអ្នកទទួលអគ្គសញ្ញាលាបថ្ងាស
# ភ្នំពេញថ្មី ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៩
# ស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នា

**អត្ថបទទី១៖ កិច្ចការ ១៤,២១ខ-២៧**

លោកដាស់តឿនពួកសាវ័កឲ្យតាំងចិត្តមាំមួន និងលើកទឹកចិត្តគេឲ្យមានជំនឿខ្ជាប់ខ្ជួន ដោយមានប្រសាសន៍ថា៖ «យើងត្រូវឆ្លងកាត់ទុក្ខវេទនាជាច្រើន ដើម្បីឲ្យបានចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់»។ កក ១៤,២២

**អត្ថបទទី២៖ វិវរណៈ ២១,១-៥ក**

ខ្ញុំឮសំឡេងបន្លឺយ៉ាងខ្លាំងៗចេញពីបល្ល័ង្កមកថា៖ «មើលហ្ន៎ ព្រះពន្លាករបស់ព្រះជាម្ចាស់ស្ថិតនៅជាមួយមនុស្សលោកហើយ! ព្រះអង្គនឹងស្ថិតនៅក្នុងចំណោមពួកគេ ពួកគេនឹងទៅជាប្រជារាស្ត្ររបស់ព្រះអង្គ ហើយព្រះជាម្ចាស់ផ្ទាល់នឹងគង់ជាមួយពួកគេ។ វវ ២១,៣

**ដំណឹងល្អ៖ យ៉ូហាន ១៣,៣១-៣៣ក.៣៤-៣៥**

បើអ្នកស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជាដឹងថា អ្នករាល់គ្នាពិតជាសាវ័ករបស់ខ្ញុំមែន។ យហ ១៣,៣៥

បងប្អូនជាទីស្រឡាញ់!

មុនព្រះយេស៊ូសោយទិវង្គត ព្រះអង្គបានរៀបចំក្រុមគ្រីស្តទូតឲ្យគេត្រៀមខ្លួន រស់នៅតាមធម្មវិន័យថ្មីស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះអង្គបានស្រឡាញ់យើង។ ពេលព្រះយេស៊ូសោយទិវង្គតហើយ ព្រះយេស៊ូបានទុកអស់រយៈពេល៤០ថ្ងៃដើម្បីបង្ហាញខ្លួន ឲ្យក្រុមគ្រីស្តទូតដែលវង្វេងអស់ហើយចាប់ផ្តើមមើលឃើញព្រះយេស៊ូផ្ទាល់ដែលមានជីវិតថ្មី ដើម្បីឲ្យគេចាប់ផ្តើមចូលនៅក្នុងគម្រោងការនៃការសង្គ្រោះយ៉ាងពិសេស។ ក្រោយមកព្រះយេស៊ូឡើងស្ថានបរមសុខដែលធ្វើឲ្យក្រុមគ្រីស្តទូតមានអារម្មណ៍ថាឯកោ ដោយសារគេមិនស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូសោះ។ ក្នុងអត្ថបទទីមួយ "**ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកដើម្បីឲ្យគេពោរពេញដោយសេចក្តីក្លាហាន**" ពេលគេពោរពេញដោយសេចក្តីក្លាហានគេទៅប្រកាសដំណឹងល្អ។ អត្ថបទទីពីរ គឺក្រុមគ្រីស្តទូតដែលបានទៅប្រកាសដំណឹងល្អនៅប៉ុន្មានភូមិ ហើយត្រឡប់មកវិញដល់ទីក្រុងអង់ទីយ៉ូត (ជាទីក្រុងពិសេសព្រោះជាកន្លែងដែលគេហៅសាវ័ករបស់ព្រះយេស៊ូជាគ្រីស្តបរិស័ទ) ដើម្បីធ្វើរបាយការណ៍ និងបង្ហាញអំពីស្នាដៃរបស់គេនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។

ក្រុមគ្រីស្តទូតដែលរស់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីប្រកាសដំណឹងល្អ ដូច្នេះខ្ញុំសូមជូន៣ចំណុចដែលចេញពីអត្ថបទដែលយើងបានស្តាប់ថ្ងៃនេះសម្រាប់គ្រូអប់រំជំនឿ។

**ចំណុចទីមួយ ធ្វើយ៉ាងណាដើម្បីឲ្យយើងណែនាំប្អូនៗដែលរៀនអប់រំជំនឿជាមួយយើងស្រឡាញ់ព្រះយេស៊ូ** នេះជាតួនាទីទីមួយរបស់យើង។ ណែនាំឲ្យប្អូនៗដែលគេរៀនអប់រំជំនឿឲ្យគេស្គាល់ និងជាពិសេសឲ្យគេស្រឡាញ់ព្រះយេស៊ូដែលគង់នៅជាមួយយើងសព្វថ្ងៃ។ ដើម្បីណែនាំឲ្យប្អូនៗស្រឡាញ់ព្រះយេស៊ូពិតៗ យើងត្រូវការគិតខ្លួនឯង**តើយើងស្រឡាញ់ព្រះយេស៊ូពិតមែនឬអត់? តើយើងបានរស់នៅក្នុងធម្មវិន័យរបស់ព្រះយេស៊ូដែលថា សូមបងប្អូនស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើងឬនៅ?** យើងមានព្រះយេស៊ូដែលជាគំរូ ដែលបានលះបង់ចោល បានលើកទឹកចិត្ត និងលើកលែងទោសឲ្យ។ ដូច្នេះតួនាទីទីមួយ សម្រាប់យើងដែលជាគ្រូអប់រំជំនឿ គឺធ្វើដូចម្ដេចដើម្បីឲ្យប្អូនៗយើង ស្គាល់ព្រះយេស៊ូយ៉ាងច្បាស់ និងស្រឡាញ់ព្រះយេស៊ូ ដើម្បីណែនាំឲ្យគេស្រឡាញ់ព្រះយេស៊ូយើងផ្ទាល់ខ្លួន ត្រូវតែស្រឡាញ់ព្រះយេស៊ូ។

**ចំណុចទីពីរ** នៅពេលលោកបារណាបាស់ជាមួយលោកប៉ូល គេបានទៅពីព្រះសហគមន៍មួយទៅព្រះសហគមន៍មួយ "**លោកដាស់តឿនពួកសាវ័កឲ្យតាំងចិត្តមាំមួន និងលើកទឹកចិត្តគេឲ្យមានជំនឿភ្ជាប់ខ្លួនដោយមានប្រសាសន៍ថា យើងត្រូវឆ្លងកាត់ទុក្ខវេទនាជាច្រើន ដើម្បីឲ្យបានចូលនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់"។ ប៉ូលនិងបារណាបាស់ ជាគំរូសម្រាប់គ្រូអប់រំជំនឿ** នៅពេលគេទៅជួបសាវ័កថ្មីៗរបស់ព្រះយេស៊ូ គេបានដាស់តឿននិងលើកទឹកចិត្ត ដោយសារគេដឹងថាអ្នកដែលបានធ្វើដំណើរថ្មីជាមួយព្រះយេស៊ូឧបសគ្គមានច្រើន ការបៀតបៀនមានច្រើន ការរិះគន់មានច្រើន។ ពេលយើងទៅតាំងគោក យើងនឹកដល់មរណសាក្សីដែលបានតស៊ូយ៉ាងច្រើននៅក្នុងជីវិតជាគ្រីស្តបរិស័ទក្នុងសម័យខ្មែរក្រហម ដែលបានខិតខំអធិដ្ឋានស្ងាត់ៗ ខិតខំសូត្រផ្តាំស្ងាត់ៗ ខិតខំអានគម្ពីរស្ងាត់ៗ ដើម្បីភ្ជាប់ជាមួយព្រះយេស៊ូគេបានតស៊ូណាស់។ ដូច្នេះគ្រូអប់រំជំនឿទាំងអស់ យើងយកចិត្តទុកដាក់ដើម្បីលើកទឹកចិត្តប្អូនៗរបស់យើង ដោយសារយើងមានការបៀតបៀន យើងមានការល្បួងច្រើននៅក្នុងសង្គមបច្ចុប្បន្ននេះ ដែលណែនាំឲ្យគេដើរតាមព្រះយេស៊ូល្មមៗចោលព្រះយេស៊ូ។ នេះជាការព្រួយបារម្ភរបស់ព្រះសហគមន៍ ប៉ុន្មានឆ្នាំនេះយើងធ្វើអគ្គសញ្ញាជ្រមុជទឹកយ៉ាងច្រើន ប៉ុន្តែក្រោយមកបាត់គេ នេះជាតួនាទីរបស់គ្រូអប់រំជំនឿ។

**ចំណុចទីបី យើងត្រូវការធ្វើដំណើរជាមួយប្អូនៗដែលកំពុងទទួលការអប់រំ និងបន្តធ្វើដំណើរជាមួយប្អូនៗដែលបានធ្វើពិធីជ្រមុជទឹកហើយ** ដោយជម្រុញគេ ដោយលើកទឹកចិត្តគេ។ សព្វថ្ងៃស្រួលណាស់ ដើម្បីទំនាក់ទំនងមិនត្រូវការសរសេរលិខិតដូចសម័យលោកប៉ូល យើងគ្រាន់តែសរសេរសារមួយខ្លីតាមទូរស័ព្ទគេទទួលបានភ្លាម។ សូមបង្កើតជាក្រុមគ្រីស្តបរិស័ទថ្មី ក្នុងបណ្ដាប្រព័ន្ធទំនាក់ទំនងសង្គមសព្វថ្ងៃតាមព្រះសហគមន៍នីមួយៗ ដោយសារបើយើងមិនធ្វើយូរៗគេ

ភ្លេចខ្លួនលែងចូលព្រះវិហារ ហើយយូរៗខ្មាស់គេលែងហ៊ានមកព្រះវិហារ។ ដូច្នេះ គ្រូអប់រំជំនឿ សូមរៀបចំក្រុមនេះ ដើម្បីដើរតាមដានប្អូនៗដែលយើងបានអប់រំ នៅក្នុងសេចក្តីស្រឡាញ់ នៅក្នុងការលើកទឹកចិត្ត និងដោយធ្វើដំណើរជាមួយគេ។ ធ្វើដំណើរជាមួយនៅក្នុងជំនឿ នៅក្នុងការលើកទឹកចិត្ត នៅក្នុងសេចក្តីស្រឡាញ់ ដើម្បីឲ្យក្រុមរបស់យើងទៅជាមហាគ្រួសារដែលរស់នៅក្នុងព្រះសហគមន៍យ៉ាងជ្រៅ នៅក្នុងអំណរសប្បាយ និងនៅក្នុងសេចក្តីសង្ឃឹមជានិច្ច។ ណែនាំឲ្យស្រឡាញ់ព្រះយេស៊ូ ការលើកទឹកចិត្ត និងធ្វើដំណើរជាមួយ នេះសម្រាប់គ្រូអប់រំជំនឿ។

ខ្ញុំមានបីចំណុចសម្រាប់ប្អូនៗដែលទទួលអគ្គសញ្ញាលាបថ្ងាសថ្ងៃនេះ អត្ថបទគម្ពីរដែលយើងអានអំបាញ់មិញ "**កាលយូដាស់អ៊ីស្ការីយ៉ូតចេញផុតទៅ ព្រះយេស៊ូមានព្រះបន្ទូល...**" ព្រះយេស៊ូបានចាំឲ្យយូដាស់អ៊ីស្ការីយ៉ូតចេញសិន។ នៅក្នុងសាវ័ក១២នាក់ដែលជិតស្និទ្ធជាមួយព្រះយេស៊ូ មានម្នាក់ដែលក្បត់ព្រះយេស៊ូ ព្រះយេស៊ូបានចាំឲ្យអ្នកនោះចេញដើម្បីនៅសល់តែអ្នកដែលមិនក្បត់ព្រះអង្គ ដែលជាមិត្តសម្លាញ់របស់ព្រះយេស៊ូ។

**ចំណុចទីមួយ សូមថែរក្សា យកចិត្តទុកដាក់នឹងមិត្តភាពជាមួយព្រះយេស៊ូ** ព្រះយេស៊ូជាមិត្តសម្លាញ់ពិសេសរបស់យើង។ ព្រះយេស៊ូអាចមានទំនាក់ទំនងជាមួយយើងយ៉ាងច្បាស់លាស់ នៅពេលយើងចេះថែរក្សាការពារមិត្តភាពនេះ នៅក្នុងការអធិដ្ឋានពីមួយថ្ងៃទៅមួយថ្ងៃ នៅក្នុងការស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូយ៉ាងច្បាស់។

**ចំណុចទីពីរ សូមថែរក្សាអំណរសប្បាយ** អំណរសប្បាយដែលយើងបានទទួលពីព្រះវិញ្ញាណដ៏វិសុទ្ធជាអំណរសប្បាយមួយដែលផ្តល់កម្លាំងឲ្យយើង ដើម្បីឈ្នះឧបសគ្គនានា ដើម្បីឈ្នះទុក្ខលំបាកដែលយើងមាននៅក្នុងជីវិត។ សូមថែរក្សាអំណរសប្បាយនៅក្នុងជីវិតផ្ទាល់ខ្លួន អំណរសប្បាយនៅក្នុងទំនាក់ទំនងជាមួយបងប្អូនឯទៀតៗ អំណរសប្បាយនៅក្នុងធ្វើការ។ សាវ័ករបស់ព្រះគ្រីស្តមានអំណរសប្បាយមួយ គឺព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

**ចំណុចទីបី សូមយកចិត្តទុកដាក់ធ្វើជាសាក្សីនៃជីវិតដែលយើងបានទទួលដល់បងប្អូនឯទៀតៗ** ដូចលោកសិលា ដូចលោកប៉ូល ដូចលោកបារណាបាស់ ដូចក្រុមគ្រីស្តទូតពីដើមឲ្យយើងធ្វើជាសាក្សីនៃអំណរដែលយើងបានទទួល សាក្សីនៃជំនឿដែលយើងបានទទួល។

សម្រាប់បងប្អូនគ្រីស្តបរិស័ទ បងប្រុសបងស្រី លោកបូជាចារ្យ លោកអភិបាល ដើម្បីធ្វើជាសាក្សីនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតប្រចាំថ្ងៃ ឲ្យយើងអនុវត្តធម្មវិន័យរបស់ព្រះយេស៊ូ "**ចូរស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នា**"។ ឲ្យយើងឆ្លាក់ព្រះបន្ទូលនេះនៅក្នុងដួងចិត្តរបស់យើងឲ្យច្បាស់ ដើម្បីគិតថា **តើខ្ញុំធ្វើដូចម្តេចដើម្បីស្រឡាញ់គេ?** មុន

យើងចូលដេកឲ្យយើងធ្វើរបាយការណ៍ទៅព្រះយេស៊ូខ្លះៗ ថ្ងៃនេះយើងបានស្រឡាញ់របៀបណា យើងបានយកចិត្តទុកដាក់នឹងបងប្អូនឯទៀតៗកម្រិតណា។ ព្រឹកឡើងឲ្យយើងនិយាយជាមួយព្រះយេស៊ូម្តងទៀត "**ឱព្រះអម្ចាស់អើយ!** **សូមអាណិតមេត្តាថ្ងៃនេះឲ្យខ្ញុំយកចិត្តទុកដាក់រស់នៅក្នុងធម្មវិន័យរបស់ព្រះអង្គអស់ពីសមត្ថភាព**"។ អាម៉ែន៕